Khmer Story Lovers

— ទីចាត់ការនៃក្រុមអ្នកនិពន្ធមាតុភូមិផ្ទះលេខ ២៩ ផ្លូវលេខ ២៨៩ ជីឡូត៍លេខ ២៩៨ បឹងកេងកង សង្កាត់លេខ ៥ ក្រុងភ្នំពេញ —

ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



អ្នករៀបរៀង: អ.គីមសាន

តម្លៃ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
«មាតុភូមិ»
ភ្នំពេញ

លេខ ២៥

## វគ្គទី .២៤

## ការខាយជរណ្ដីមផ្លាកបញ្ញា

អស់ទាំងពីរនាំគ្នាស្ទុះមកជិតមាណពស្សួរ :

–ឯងជាអ្នកណា, មកទីនេះមានការអី ?

សំដីអសីបែបព្រហើនបង្អិចព្រោះគេឃើញមាណពស្លៀកពាក់ប្រឡាក់ប្រឡូស ទឹកមុខមិនមាំមាំ បែបមិនគ្រប់ជប់, គេស្មានថាខាយល្ងង់ខ្លៅណាស់, តែសុំផុតមានឥតប្រកាន់ទេ នាយឆ្លើយដោយស្រួល :

–បាទ, ខ្ញុំគ្មានការអីទេ ។ ទីនេះជាវត្តការាមឬ ? បើមានសេសសល់បាយទឹក ឲ្យខ្ញុំសុំទទួលទានបន្តិចមក ។

អសីមួយប្រេតហក :

–អាចំកួត និយាយផ្ដេសផ្ដាសម្ល៉េះ ? ឯងមើលមកពួកយើងស្មានថាលោកសង្ឃឬ ? ចេញឲ្យឆាប់ទៅ, កុំហ៊ានមករំខានយើង, ប្រយ័ត្នយើងវាយបាក់ស្មងជើង !

អសីមួយទៀតកងក្មេង ស្ទាបជងវាវសម្លក់សម្លឹងខាយ ដូចចង់វាយប្រដៅ, មាណពសើចស្ញេញពោលបន្ត:

–បើមិនមែនវត្តគឺអាស្រមឥសីហើយ ។ ខ្ញុំឃ្លានណាស់, មករកចំណីអាហារចំអែតការគ្នាទេ, ឥតចង់វាយតបអីទេ

នៅស្ងៀមៗសោះ មិនគួរធ្វើឲ្យគេស្លាប់ពីនាក់ទៀតទេ ។

នាយពោលបណ្ដើរដើរចេញទៅវិញបណ្ដើរ ។ ឥសីរូបក្មេងគំហកសួរទៀត:

-ឯងនិយាយថាម៉េច ?

ពោលហើយដេញតាមនាយក្វាម ។ សំដីស៊ីផានមួយម៉ាត់នេះចំជាត្រូវព្រោះនៅក្នុងបន្ទប់សម្ងាត់ នាយគ្រាន់តែលើកដៃ សមាជិកក្រុមប្លុកដែកស្លាប់ក្វាម នាយសោកស្ដាយណាស់មិនងាប់ចិត្តលើកដៃប្រយុទ្ធជាមួយអ្នកដទៃទៀតឡើយ ។ ព្រោះហេតុខ្លាចជ្រុលដៃជ្រុលជើងហ្នឹងហើយ បានជានាយប្រញាប់គេចពីឥសីរូបក្មេងចូលព្រៃបាត់ ។ ឥសីតាំងពីរសើចហាសហាយ... ម្នាក់ឯងលថា :

- អាក្មេងនេះចំឡែកណាស់, គ្រាន់តែសំឡុតបន្តិចក៏រត់បាត់ជើងសព្រាតក្វាម ។

ស៊ីផានពួនក្នុងព្រៃមិនយូរប៉ុន្មានមេឃងងឹតល្អប់នាយចង់រកបេះផ្លែឈើទទួលទាន តែគ្មានសោះ ព្រោះព្រៃនោះមានដើមស្រល់ច្រើនជាងរុក្ខជាតិឯទៀតឥតមានផ្លែសោះ ។ នាយឡើងលើដំបូកមួយសន្ដឹកសង្កេតទិសឃើញអគារតូចៗ តាមជាយភ្នំប្រហែលបួនដប់ខ្នងសង់ក្បែរអាស្រមធំ ។ អគារក្រោយគេបង្អស់មានហុយផ្សែងខ្មួលៗតាមដំបូលសយជាទីកន្លែងដណ្ដាំស្ល ក្រៅពីអាស្រមធំនៅកណ្ដាលនិងអគារតូចៗ នាយមិនឃើញផ្ទះសម្បែងអ្នកស្រុកមួយឡើយ ។

គ្រាន់តែឃើញផ្សែងនាយក្ករពោះគ្រូកៗនឹកថា:

- ឥសីអស់នេះកាចណាស់រ៉ុយ, ហាមាត់ឡើងរកតែវាយគប់គ្នា ។ តម្រូវយើងទៅមើលខាងក្រោយសិន, ឲ្យតែមានស្លស៊ីបាន ល្អបតែម្ដង !

នាយដើរកាត់ព្រៃវាងទៅក្រោយអគារមានផ្សែងហុយសសៀរតាមរបង អើតគល់បមើលឃើញទ្វារក្រោយបើកស្រាប់ក៏ប្រាថ្នាចូលទៅក្វាម ។ ពេលនេះមេឃងងឹតមើលអ្វីមិនច្បាស់ទេ ។ ផុតទ្វាររបងមានទីធ្លាមួយទៀត, នាយឈប់ស្ដាប់ឮសម្លេងដែកគ្នាអូរ ព្រមទាំងសម្លេងវែកខ្ទះចូកម្ហូបឆៅៗ ពោលក្លិនឈ្ងុយឆ្ងាញ់ ធ្វើឲ្យមាណពរិតតែឃ្លានម្ហូបពោះគ្រូកៗ ស្រក់ទឹកមាត់ប្រោក ។ នាយលេបទឹកមាត់ក្អឹកៗ ដកដង្ហើមស្រូបក្លិនម្ហូបនឹកថា : ក្នុងផ្ទះបាយនេះពិតជាមានមនុស្សច្រើនណាស់ យើងមិនហ៊ានអើតក្បាលទេខ្លាចគេឃើញកើតរឿងទៀត ។ នាយលបទៅពួនត្រង់ច្រកមួយងងឹតល្អប់សម្លឹងទ្វារផ្ទះបាយនឹកថា :

– ចាំមើលពួកគេដញ្ចូនម្ហូបអាហារទៅកន្លែងណា ? បើគេរៀបទុកចោលសិនយើងលួចមួយបានតែគ្រួយ ទើបចៀសវាងការវាយតប់បាន ។

មែន ! មួយសន្ទុះក្រោយ នាយឃើញស្ត្រីបីនាក់ដើរមក ។ ម្នាក់កាន់ចង្កៀងគោមបំភ្លឺផ្លូវ ពីរនាក់ទៀតកាន់ថាសមានផែងហុយទ្រលោម ធុំក្លិនឈ្ងុយឆ្ងាញ់ប្រហែលសាច់មាន់ឬទាខ្វៃហើយ ។ មាណពលេបទឹកមាត់ក្លឹក ១ ទាល់តែស្រូតបំពង់កហើយលបដើរតាមក្រោយយ៉ាងស្ងាត់ស្ងៀម ។

ស្ត្រីទាំងបីដើរតម្រង់បន្ទប់មួយនៅខាងមុខ ហើយដាក់ថាសម្ហូបលើតុធំកណ្តាល, ស្ត្រីពីរនាក់ចេញមកវិញ នៅសល់ម្នាក់ចាំជូតតុរៀបចំចាន , ស្លាបព្រា , ចង្កឹះ ដោយថ្លិតថ្លន់ ។ ស៊ីផានទៅក្រោមបង្អួចលបមើលដោយធុញទ្រាន់ណាស់ ព្រោះឃ្លានពេក ។ បើមិនខ្លាចស្លាប់ស្ត្រីរូបនេះ ម្ល៉េះសមនាយហក់លោតទៅដណ្តើមបាយសម្លមកទទួលទានហើយ ។

មាណពចាំអត់ទ្រាំទាល់តែស្ត្រីម្នាក់នេះរៀបចំរួចស្រេចពេញចិត្តទើបដើរទៅក្រៅបាត់ នាយលោតផ្លោតចាប់សាច់ចៀនមួយដុំញាត់មាត់ផ្លុប, ដៃម្ខាងចាប់ហែកជើងមាន់គាំង...

ទើបតែទំពារសាច់ចៀនបានមួយមាត់ស្រាប់តែឮសម្លេងមកពីក្រៅ:

– ប្អូនប្រុសនិងប្អូនស្រីអញ្ជើញមកខាងណេះ !

ស៊ីផានឮស្នូរជើងជាច្រើនដើរតម្រង់មកបន្ទប់នេះយឺតៗ ទំនងម្ចាស់ផ្ទះជូនដំណើរភ្ញៀវ ។ នាយភ័យប៉ប្អកញាត់សាច់ក្នុងមាត់មួយដុំធំហើយលូកចាប់សាច់មួយដុំទៀតប្រុងរត់តាមទ្វារក្រោយ តែនាយឮស្នូរជើងមកពីក្រោយដំណាលគ្នារកច្រករត់មិនឃើញ ។ នាយក្រឡេកក្រឡេករកកន្លែងពួនក៏មិនឃើញទៀតព្រោះបន្ទប់នេះល្វឹងល្វើយ ។ នាយភ័យខ្លាំងឡើងនឹកថាម្តងនេះបែបចៀសមិនផុតពីការវាយគ្នាទេ ។

ស្នូរជើងកាន់តែមកជិត , មាណពស្រមៃឃើញវិការផ្លូនខ្ទាចផ្សា ក្នុងបន្ទប់សម្ងាត់នៃក្រុមច្បូកដែក , ឃើញសមាជិកអស់នោះដួលស្លាប់ប្រុស ១ ដូចត្រូវបណ្តាសាព្រះអាទិទេព ។

នាយស្មានអ្នកអស់នោះត្រូវខ្មោចព្រាយធ្វើទុក , មិនមែនស្លាប់ដោយស្នាដៃនាយក៏ដោយពេលនេះនាយមិនហ៊ានសាកល្បងវាយនរណាទៀតឡើយ ។ នាយព្រឺក្បាលសំពោង បែកញើសដាក់ក្បាល ពេលភ្នែកមើលលើម្តងឃើញក្តារមួយបន្ទះធំ ព្យួរចំកណ្តាលបន្ទប់ មានឆ្លាក់អក្សរ

**ធំ ។** លាបទឹកមាស ។ នាយមិនបង្អង់ទៀយ , ទន្ទ្រាំដើរលោតផ្លោតតោងបន្ទះក្តារ ពួនពីក្រោយបាត់ ល្មមពេលដែលទ្វារបន្ទប់ត្រូវគេប្រានបើក ហើយឮមាត់មនុស្សនិយាយ :

- បងប្អូនគ្នាសោះ មើលលោកបងគួរសមម៉្លេះ ?

ស៊ីផានភ្ញាក់ព្រើតហាក់ធ្លាប់ស្គាល់សម្តីនេះ ម៉្លោះហើយនាយលបមើលតាមប្រឡោះក្តារឃើញ ឥសីបួនដប់រូបនាំបុរសនិងស្រ្តីដើរចូលមក ។ គឺជាម្ចាស់ភូមិហាំនសាន់ស៊ូឈ្មោះ ស៊ុឈង់និងភរិយាតែម្តង ។

ស៊ីផានមានសមានចិត្តចំពោះអ្នកទាំងពីរណាស់, ជាពិសេសនាយស្រឡាញ់រាប់អានអ្នកស្រីវ៉ុនយូ ដែលស្លូតបូតចិត្តល្អ បានឲ្យប្រាក់នាយចាយហើយបង្ហាត់សៀវភៅគុនជាថ្មីទៀត ។ នាយឃើញអ្នកទាំងពីរក៏កើតមានការតក់ក្តៅមួយរំពេច ។

ពេលនោះឥសីចំណាស់មួយរូប សក់ស្កូវព្រោងពុកមាត់សវែង ថ្លែងថា:

- ប្អូនប្រុស , ប្អូនស្រីមកពីឆ្ងាយ បងត្រូវតែស្រាវជ្រាវខ្លះ ជាការធម្មតាទេតើ !

ពោលដល់នេះ គាត់ក្រឡេកទៅលើតុឃើញប្រឡាក់ខ្លាញ់ ; សាច់បៀនបាត់ខ្វះពីកន្លែងបាន ហើយចានមួយទៀតទទេស្អាតនៅសល់តែខ្លាញ់, គាត់ឥសីជ្រួញចិញ្ចើមដោយមិនពេញចិត្ត និតថា

- ពួកនេះប្រវ័ហានណាស់ , រៀបចំបាយទឹករួចហើយ មិននៅមើលបណ្តោយឲ្យឆ្មាលួចស៊ីអស់ ប្រឡាក់ប្រឡូសពេញតុ ។

ឥសីមិនហ៊ានបន្ទោសសិស្សព្រោះមានភ្ញៀវ ក៏នៅស្ងៀម ។ ឯឥសីក្មេង ១ លើកប្អូប មកទៀតឃើញការប្លែកនៅលើតុ គេបញ្ចេញអាការៈភ័យតក់ស្លុតប្រញាប់ប្រញាល់ជូតតុមិនរៀបចានឡើងវិញ ស្រួលបួលឥតមាត់ក ។

ឥសីចំណាស់អញ្ជើញស៊ុឈង់និងអ្នកស្រីវ៉ុនយូអង្គុយកន្លែងកិត្តិយស, ខុនគាត់និងឥសីមួយរូបទៀតអង្គុយកំដរសងខាង, ឥសីដប់ពីររូបអង្គុយកំដរជុំវិញតុពីក្បែរនោះដែរ ។

ក្រោយពីពុកប្រាំម្នាក់បន្តិចមក, ឥសីចំណាស់ដកដង្ហើមយូរ ផ្តើមពោលថា :

- វែកគ្នាប្រាំបីឆ្នាំ, ប្អូនប្រុស ប្អូនស្រីនៅក្លាហានអង់អាចដដែល, ចំណែកបងវិញចាស់ជរា ធ្វើការអ្វីលែងបានហើយ !

**ស៊ុឈង់តប :**

- លោកបងស្លូតខ្លះមែន តែនៅមានសុខភាពបរិបូណ៌ដដែល ។

- ទេ ! សក់ស្កូវខ្លះឯណា ? បងព្រួយតែសក់ក្បាលប្រែសរូវតែក្នុងមួយថ្ងៃទេ ! បើប្អូនប្រុសស្រីមកដល់ទីនេះមុនបីថ្ងៃប្អូននឹងឃើញសក់បងល្បាយកាចម៉ខ្មៅប៉ុណ្ណោះ មិនស្កូវអស់ដូចថ្ងៃនេះឡើយ ។

- លោកបងព្រួយបារម្ភដោយសាររឿងសេនាបញ្ញាមរណៈនោះឬ ?

ឥសីដកដង្ហើមធំម្ដងទៀត :

-បាំ ! ក្រៅពីរឿងសេនាតាំងពីរប្រហែលគ្មានរឿងអ្វីអាចធ្វើឲ្យឥសីធានស៊ុនៅអាស្រមសាំងឈីង ប្រែសក់ក្បាលពុកចង្កាពីខ្មៅទៅសក្នុងមួយយប់នោះទេ ! មួយយប់បងចាស់ដូចម្ភៃឆ្នាំអីចឹង !

ស៊ីឈីងឈឺឆ្អាលចំពោះរឿងឥសីកស្បូរទៀត:

-ខ្ញុំនិងអូនយូគ្រាន់តែព្រឺដំណឹងថា សេនាបញ្ញាមរណៈចេញប្រតិបត្តិការក្លាយខ្ញុំបារម្ភណាស់ដឹងថា ពិតពិតនឹងយើងពិតជួបប្រទះគ្រោះភយក្ដុកយទៀតហើយ ។ ព្រោះហេតុនេះបានជាខ្ញុំស្រូតដំណើរ តាំងយប់អធ្រាត្រមកពិភាក្សាជាមួយលោកបង ។ ក្បែកអាស្រមសាំងឈីងមានឈ្មោះល្បីខ្ទរខ្ទារ ច្រើនឆ្នាំមកហើយ ពាក្យចាស់លោកថា "ឈើចាស់ដក់ខ្យល់"... សេនាតាំងពីរប្រហែលមកកាន់ទីនេះ ពុំខាន ។ ខ្ញុំគិតថានៅសំណាក់ទីនេះប្អូនទាំ ក្រែងសេនាបញ្ញាមរណៈហ៊ានមកមែន... ខ្ញុំជួយ ក្រោមវៃជ្រងលោកបងតាំងអស់ការពារក្រុមយើងឲ្យគង់វង់ តាមលទ្ធភាពដែលជួយបាន ។

ឥសីធានស៊ុងឹងឥសីម្នាក់ក្បែរនេះមើលមុខគ្នាដកដង្ហើមធំ ។ បន្ទាប់មកធានស៊ុលូកផ្លាក ស្ពានពីរផ្ទាំងពីហោប៉ៅបោះលើតុងឹង ។ ។

ស៊ីងធានមើលពីលើឃើញឡាស់ណាស់, ផ្ទាកមួយមានគូររូបមុខមនុស្សសើចគ្របាញ, មួយទៀតមុខមនុស្សកាចសាហាវពិតជាផ្លាកស្ពានដែលនាយបានឃើញពីរងនិរូចមកហើយ ឬងនៅក្នុងទូកក្រុមត្រីហោះម្ដងទៀតនៅក្នុងបន្ទប់សម្ងាត់នៃក្រុមឡូកវែក ។ នាយបុកពោះភឹបៗដណ្ដឹងសួរថា ឥសីធានស៊ុបានផ្លាកស្ពានមកពីណា ?

ពេលនោះស៊ុឈីង លាន់មាត់:

យើ ! សេនាបញ្ញាមរណៈបានមកដល់នេះហើយឬ ? ខ្ញុំខំប្រញូតដំណើរតាំងថ្ងៃតាំងយប់នៅមកមិនទាន់ទេ ! តើគេមកដល់ពីការណា, ហើយលោកបង . . . លោកបងធ្វើម៉េចដែរ

ជានស៊ីក្ដុកក្ដួលអួលអើកតែពាក្យឆ្លើយមិនរួច, ឥសីញាក់ក្បាលទោ·

- ពួកគេមកដល់តាំងពីថ្ងៃមុនម៉្លេះ ។ លោកបងគិតប្រយោជន៍រួម ទើបសុខចិត្តទទួល បញ្ហាទៅពិសាបបរខែកត្ដិក នៅទីនោះ ។

ស៊ុយឈីងមានការសង្ស័យតាំងពីចូលផុតខ្លោងទ្វារអាស្រមឃើញសភាពស្ងប់ស្ងាត់ និងទឹកមុខលោកឥសីម៉្លេះ មិនបាច់សួរក៏ដឹងដែរ ។ គាត់ស្ទុះក្រោកក្រែតលំទោនកាយធ្វើគារវកិច្ចចំពោះឥសីជានស៊ីពោលថា :

- លោកបងទទួលអម្រែកដ៏ធ្ងន់នេះតែម្នាក់ឯង ដើម្បីសេចក្ដីសុខនៃយើងខ្ញុំទាំងអស់ , ខ្ញុំរំភើបហើយគោរពស្ញប់ស្ញែងលោកបងណាស់ , សូមថ្លែងអំណរគុណទុកជាមុន ។ ពេលនេះខ្ញុំមានរឿងមួយចង់ស្នើនឹងលោកបង , សូមលោកបងមេត្តាអភ័យទោសផង ។

ឥសីជានស៊ីញញឹម :

- ប្អូនអើយ, ជីវិតសត្វលោកមិនទៀងទាត់ទេ ដុំពពកអណ្ដែតត្រសែតតាមខ្យល់ផ្លូវឆ្ងាយឯង ។ មានការអ្វីប្អូននិយាយមកចុះ, បងសុខចិត្តទាំងអស់ ។

- អូ, លោកបងយល់ព្រមតាមខ្ញុំឬ ?

ឥសីជានស៊ីងក់ក្បាល :

- ព្រមហើយ, មានការអីនិយាយមកមើល ?

- ខ្ញុំសុំចិត្តលោកបង, សុំលោកបងផ្ទេរតំណែងនាយក្រុមអាស្រមសាំងឈីង មកឲ្យខ្ញុំកាន់កាប់ម្ដង ។

សេចក្ដីស្នើនេះធ្វើឲ្យឥសីទាំងអស់ភ្ញាក់ផ្អើលគ្រប់គ្នា, ជានស៊ីសញ្ជឹងគិតយ៉ាងស្ងៀមស្ងាត់ ។

ស៊ុយឈីងបន្ត :

-បើលោកបងឲ្យខ្ញុំនឹងអូនយូកាន់កាប់តំណែងនេះ ខ្ញុំត្រូវចូលរួមពិធីទទួលទានបបរខែកត្តិកជំនួសលោកបងវិញ ។

ឥសីជានស៊ីស្ដាប់ចប់ទឹកអស់សំណើច តែសំណើចក្រៀមស្រពោន ពោរពេញទៅដោយការសោកសៅ ។ ឥសីឆ្លើយតបវិញទាំងទឹកភ្នែករលីងរលោង:

- បងសុំថ្លែងអំណរគុណចំពោះប្អូនច្រើនណាស់, តែរូបបងដឹកនាំអាស្រមសាំងឈីងជាងដប់

Khmer Story Lovers



ឆ្នាំមកហើយអ្នកណាក៏ដឹងដែរ ។ ថ្ងៃនេះជួបប្រទះគ្រោះថ្នាក់. ប្អូនឲ្យបងគេចវៀរដូចកណ្ដុរមិនល្អមើលទេ, ប្អូនឲ្យបងយកមុខទៅទុកឯណា ?

ឥសីពោលដល់នេះលូកចាប់ដៃស៊ុយឈីន យ៉ានណៃនបន្ត:

- ប្អូនប្រុស, យើងមានវ័យខុសគ្នាឆ្ងាយណាស់ , ប្អូនមិនមែនជាអ្នកកាន់សីលហើយឥតបានទៅជិតដិតជាមួយបងផង, យើងមិនសូវបាននិយាយគ្នាញឹកញាប់ទេ ។ ប៉ុន្តែពេលនេះបងយល់ចិត្តប្អូនណាស់ , បងសុំស្ងើចសរសើរទឹកចិត្តក្លាហាននិងកិត្តិយុទ្ធសិល្បៈរបស់ប្អូនដោយស្មោះ ។ បើកុំតែជាប់ពាក្យសច្ចាទទួលតាមបបរខកក្តិកនេះ បងផ្ទេរតំណែងនាយក្រុមឲ្យប្អូនយ៉ានរីកកាយ ។ ថ្ងៃនេះព្រឹត្តការណ៍វិវត្តខុសអស់ហើយ, បងមិនអាចយល់ព្រមតាមសេចក្ដីស្នើរបស់ប្អូនទេ ។ ហាស ! . . . ហាស ! . . .



ឥសីសើចសោះកក្រោះ ដូចជាខ្លោចផ្សាណាស់ ។ ស៊ីផានពូនស្ដាប់ឥតបមោះមួយម៉ាត់ ដោយទឹកឆ្ងល់ណាស់ មិនដឹងតើបបរខកក្តិកនោះជាវត្ថុអ្វី ? កាលនៅក្នុងវង់ក្រុមប្លុកដែក នាយពូចានស នាំពួកម្ដងដែរ, ពេលនេះទៀត គ្រាន់តែពោលដល់ឈ្មោះបបរខកក្តិក ឥសីពានស៊ីបក្រោញអាការៈប្លែក... បបរខកក្តិកជាពិសកាចសាហាវទេដឹង ?

ឥសីធានស៊ីសើចចប់ ពោលបន្ត:

- ប្អូនប្រុសកុំយល់ច្រឡំឲ្យសោះណា ! សក់ក្បាលបងប្រែពណ៌តែក្នុងមួយយប់នេះ មិនមែនបានសេចក្ដីថាបងខ្លាចស្លាប់ទេ ។ បងកាយុហុកសិបពីរឆ្នាំ ស្លាប់ក្នុងឆ្នាំនេះក៏មិនចាស់ខុសដែរ , មិនមែនអាយុខ្លីទេ ។ បងព្រួយដោយខំនឹកស្រាវជ្រាវរកបញ្ហាបាយកំចាត់គ្រោះចង្រៃនពិតពត្ត ដែលកើតមានឡើងជាប់ឆ្នាំប្ដូរៗ នេះឯង ។ បងគិតថា តើយ៉ាងណាឲ្យក្រុមបក្សយើងគេចផុតពីភ័យសក្តិនាមបានរហូតទៅ ! ហ៊ឺ ! រឿងនេះពិបាកណាស់ , សាមសិបពីរឆ្នាំនេះ គេបានរៀបចំពិធីជប់លៀងបបរខកក្តិកបីដងហើយ ! អ្នកក្លាហានគ្រប់ក្រុមគ្រប់បក្ស

ឲ្យតែយល់ព្រមតាមសេចក្ដីអញ្ជើញ , អ្នកនោះមិនដែលបានត្រឡប់មកវិញឡើយ ។ ការស្លាប់របស់បងផ្ទាល់មិនសំខាន់ប៉ុន្មានទេ , តែយើងត្រូវគិតដល់អនាគតណា ប្អូន ! ត្រូវខិតខំរកមធ្យោបាយការពារក្រុមបក្សយើងផង ។

ស៊ុយឈីងស្ដាប់ចប់ស្រាប់តែធ្លាយសំណើចក្អាកក្អាយលើកកែវស្រាផឹកក្អឹកៗ ទាល់តែអស់ទើបឆ្លើយ:

– លោកបងមិនជ្រាបទេ, ខ្ញុំស្នើលោកបងឲ្យផ្ទេរតំណែងនាយក្រុមមកនេះ មិនមែនចង់ទៅស្លាប់ជំនួសលោកបងទេ ។ ខ្ញុំចង់ទៅស៊ើបការផ្ទាល់ក្នុងកម្ពង់ណា ក្រែងទេវតាជួយអាចរកឃើញអាថ៌កំបាំង បានខ្ញុំនឹងផ្សាយដំណឹងដល់អ្នកគុននិយមគ្រប់រូបប្រួតដៃគ្នា កំចាត់ជនអប្រិយទាំងនោះវិនាសសាបសូន្យពីមុខពីមាត់យើង ។

ជានស៊ុក្រវីក្បាលមួយៗ:

– បងមិនមែនអួតសរសើរគេ ហើយបន្ទាបគ្នាឯងទេ ។ ប្អូនគិតមើលឥស៊ីយីមុខានបក្សអ៊ូតាំង និងឥស៊ីយីផិនខានបក្សឈីងសេង សុទ្ធតែជាកំពូលអ្នកក្លាហានជំនាន់មុន ម្ដេចឡើយទៅបាត់គ្មានត្រឡប់ដែរ ? ប្អូនមានគុនវិជ្ជាខ្ពង់ខ្ពស់មែនហើយ តែ ... បែបមិនអាចប្រៀបផ្ទឹមនឹងអ្នកក្លាហានជំនាន់មុនទាំងពីររូបបានទេ ។

– បាទ , រឿងនេះខ្ញុំយល់ណាស់ , តែខ្ញុំថាដោះស្រាយបញ្ហានីមួយៗ មិនមែនពឹងផ្អែកលើកម្លាំងកាយតែមួយមុខទេ, ត្រូវប្រើកម្លាំងប្រាជ្ញារួមជាមួយហើយសង្ឃឹមលើព្រេងសំណាងផង ទើបគ្រប់គ្រាន់ ។ រឿងបង្ក្រាបពួកសាហាវយង់ឃ្នងនោះគ្មានផ្លូវទេ , ខ្ញុំហ៊ានតែត្រឹមស៊ើបដំណឹងឲ្យច្បាស់លាស់ជាងនេះប៉ុណ្ណោះ ។

ជានស៊ុនៅតែក្រវីក្បាល:

– តំណែងនាយក្រុមអាស្រមសាំងឈីងយើងនេះធ្លាប់នៅក្នុងកណ្ដាប់ដៃអ្នកកាន់ស៊ីលទាន, ហេតុនេះបងត្រូវផ្ទេរតំណែងឲ្យប្អូនឈុងស៊ីវិញ ។ កាលណាបងស្លាប់ទៅ, សូមប្អូនប្រុសប្អូនស្រីជួយមើលផង , កុំឲ្យក្រុមយើងសាបសោបកេរ្តិ៍ឈ្មោះ ។ តែប៉ុណ្ណឹងបងត្រេកអរណាស់ទៅហើយ ។

ស៊ុយឈីងនិយាយពន្យល់ទាល់តែស្អកក៏ជានស៊ុមិនយល់ស្រប ។ អ្នកទាំងអស់ដាក់កែវស្រា

ចុះក្មួយទទួលទានម្ហូបអាហារអស់ ។ ស៊ីផានពូនស្លាប់គេផងហែកសាច់តូច ៗ ដាក់ក្នុងមាត់ ផងឥតហ៊ានចំពារខ្លាចគេឮ , ភ្នែកទាំងពីរក៏បើកគ្រលួនមើលមកក្រោមឥតហ៊ានព្រិចដែរ ។

អ្នកស្រីវុនយូអង្គុយស្ងៀមស្តាប់ប្តីជជែកជាមួយឥសីផានស៊ី ។ ពេលនេះស៊ីផានឃើញ គាត់លូកដៃសន្សឹមៗយកផ្កាកស្លាន់ទាំងពីរមកមើលបន្តិច ហើយប្រុងដាក់ក្នុងហោប៉ៅទុក ។ ឥសី ផានស៊ីឃើញទាន់ស្រែកឃាត់ :

-ប្អូនស្រីដាក់ចុះវិញមក !

វុនយូញញឹម :

-ទេ, ខ្ញុំថែរក្សាជំនួសលោកបងក៏ដូចគ្នាដែរ ។

ពោលហើយនាងទុកផ្កាកស្លាន់ក្នុងហោប៉ៅម្តងទៀត ។ ឥសីផានស៊ីយល់ថាឃាត់អ្នកស្រី មិនឈ្នះទេក៏លូកដៃដណ្តើមភ្លាម ។ តែពេលនោះស៊ីឈើងលូកបង្អើះចាប់សាច់ដែរ ឥសីក៏ទាក់ ទានមួយគ្រា ។ ឥសីមួយរូបឈ្មោះ ឈុងស៊ី ដែលអង្គុយក្បែរឥសីផានស៊ីលូកដៃចាប់ផ្កា ស្លាន់ស្រែកថា :

- ឲ្យខ្ញុំទុកវិញ !

អ្នកស្រីស៊ីលើកដៃឆ្វេងផ្ទាត់ម្រាមដៃទាំងបួនលើដៃឥសីឈុងស៊ីដូចគេកេះខ្សែតាប៉ី ។ ឈុង ស៊ីក៏ហារម្រាមឆ្វេងពុចជីពចរកដៃអ្នកស្រីវិញដែរ.អ្នកស្រីដកដៃផ្ទាត់ចេញរហ័សលឿន ' លើទ្រូងឥសីភ្លាម ។

ឥសីឈុងស៊ីត្រូវតែងតាំងជាតាយក្រុមជំនួសឥសីផានស៊ីខាងកាស្រមសាំងឈើងនេះមកពីគាត់មាន កិត្តិយុទ្ធសិល្បៈ ខ្ពង់ខ្ពស់ជាងសិស្សទាំងអស់ ។ ទោះដឹងថាស៊ីឈើងមិនគិតយ៉ាប្រព្រឹត្តបែបនេះ ដើម្បីជួយជីវិតឥសីតាយក្រុមក៏គាត់មិនសុខចិត្តឲ្យប្តីប្រពន្ធនេះដណ្តើមផ្កាកស្លាន់បានដែរ, ព្រោះឥសី ផានស៊ីជាអ្នកទទួលពីសេនាបញ្ជាបរណៈ មិនត្រូវឲ្យផ្កានេះធ្លាក់ក្នុងកណ្តាប់ដៃអ្នកដទៃកើតការ អាសន្ន ពុំទេ ។

គាត់តាំងចិត្តថាដណ្តើមផ្កាកស្លាន់ពីអ្នកស្រីឲ្យទាល់តែបានម៉្លោះហើយ ក្នុងមួយភ្លែតនោះគេប្តូរស្នៀត ទៅវិញទៅមកប្អូនថប់ភ្លាម ។ អ្នកទាំងពីរអង្គុយនៅកន្លែងដដែលសំដែងវិជ្ជាចាប់ខ្ទាំប្រចាំក្រុម បក្សដូចគ្នា ព្រោះគេជាសិស្សរួមគ្រូតែមួយ ។ គូប្រយុទ្ធគ្មានបំណងធ្វើឲ្យរបួសម្ខាងៗទេ, ប៉ុន្តែ ការប្តូរស្នៀតយ៉ាងរហ័សរហួនបែបនេះមិនខុសពីការប្រយុទ្ធគ្នាមែនទែនឡើយ ។

អ្នកទាំងពីរបែកគ្នាជាងម្ភៃឆ្នាំហើយទោះបានជួបជុំម្តង ១ គឺមិនដែលបានសាកល្បងថ្វីដៃឲ្យពេញដៃពេញជើងដែរ ។ ពេលនេះបានឱកាសប្រឡូកគ្នាដូច្នេះ ទើបនឹកស្ងើចសរសើរគូប្រយុទ្ធរៀង ៗខ្លួន ។ ចំណែកពួកឥសីឯទៀត ក៏ទម្លាក់កែវចង្កឹះលើតុហើយសម្លឹងមើលគេប្រយុទ្ធមិនដាក់ភ្នែកដែរ ។

ជនទាំងនេះសុទ្ធសឹងអ្នកក្លាហានប្រចាំ អាស្រមសាំងឈីង គេដឹងថាប្តីប្រពន្ធស៊ុយឈីងមានឈ្មោះល្បីរន្ទឺជាងដប់ឆ្នាំហើយ ហើយពេលនេះបានឃើញថ្វីដៃនុងយូផ្លាល់ភ្នែកប្រកបដោយកម្រិតយ៉ាងខ្ពស់ មែនក៏កើតចិត្តគោរពស្ញប់ស្ញែងក្រៃលែង ។

ក្នុងចំណោមអ្នកទាំងអស់ គ្មាននរណាម្នាក់ចាប់ភ្ញាក់ថាមានមនុស្សផ្សេងលបលួចតាមដានការប្រយុទ្ធដណ្តើមផ្កាកស្ពាន់ពីលើមេកឡើយ ។

ក្នុងប្អូនដប់ស្បៀតដំបូងមានការប៉ះស្មើគ្នា ដល់ក្រោយមកអ្នកស្រីអន់ជាងឥសីបន្តិច ព្រោះគាត់រវល់កាន់ផ្កាកស្ពាន់ក្នុងដៃស្តាំ សំដែងបានតែស្បៀតគុនប្រដាល់មួយមុខ, សល់ដៃឆ្វេងទើបអាចបញ្ចេញស្បៀតខ្លះ, ចាប់ចុំបានតាមចិត្ត ។ មួយស្របក់ក្រោយឥសីឈុងស៊ីសន្ធាត់ដៃឆ្វេងលើដៃឆ្វេងអ្នកស្រីនុងយូ, អ្នកស្រីនឹកថាពិតជាឥសីដណ្តើមបានហើយ, បើប្រើកម្លាំងកាយទាញទៅទាញមកដូចជាមិនសូវសម, ណាមួយខ្លួនជាស្រី កម្លាំងខ្សោយផង មិនដឹងធ្វើម៉េចគាត់លែងដៃទម្លាក់ផ្កាកស្ពាន់លើតុចំមុខស្វាមី ។

ស៊ុយឈីងលូកដៃក្តោបប្រុងរើសយក ស្រាប់តែមានខ្យល់ដៃម្នាងណោះបោកបក់មកវិញ ១ កាត់មុខគាត់ គឺឥសីបានស៊ីចះមកពីដៃយ៉ាងខ្លាំងក្លានោះឯង ។ ស៊ុយឈីងយល់ថាត្រាំត្រង់ក៏មិនឈ្នះ ទទួលខ្យល់ដៃនេះគឺរបួស ដណ្តើមបានផ្កាកស្ពាន់ក៏ឥតប្រយោជន៍ ទើបប្រញាប់លើកដៃទប់ទល់បន្ទន់ល្បឿនឥសី ។

ឥសីមួយរូបអង្គុយតុក្បែរនោះ ឃើញឱកាសល្អមកដល់ហើយ ក៏ស្ទុះក្រោកភ្លូកមកចាប់ផ្កាកស្ពាន់បានយ៉ាងងាយ ។

និមិត្តផ្កាកស្ពាន់ទាំងពីរទៅនៅក្នុងដៃឥសីតាវស៊ុំកាលណា, ប្តីប្រពន្ធស៊ុយឈីង, ឥសីតាន ស៊ីនិងឈុងស៊ុក៏សើចហាសហាយដកដៃរៀងខ្លួនឈប់ប្រយុទ្ធគ្នាភ្លាម ។ ឥសីឈុងស៊ីនិងតាវស៊ុ ក្រោកឈរព្រមគ្នាលំទោនកាយបន្ទាបថា :

- សូមលោកប្អូនប្រុស, ប្អូនស្រីអភ័យទោស !

ប្តីប្រពន្ធស៊ីឈីងប្រញាប់ស្ទុះក្រោកឈរធ្វើគារវកិច្ចតបវិញ ។ ស៊ីឈីងតបៈ

– លោកបងទាំងពីរមើលទៅមានប្រសាសន៍បែបហ្នឹង ? គឺរូបខ្ញុំទេតើដែលបង្កហេតុមុន ។ គិតទៅកម្លាំងធាតុលោកនាយក្រុមខ្លាំងក្លាណាស់, ទោះដំណើររឿងប្រកបដោយគ្រោះថ្នាក់យ៉ាងណាក៏ប្រហែលលោកអាចដកខ្លួនបានដែរ ។

ស៊ីឈីងពោលបែបនេះដោយហេតុអម្បាញ់មិញគាត់ស្តាប់ស្គាល់ដឹងកម្លាំងធាតុលោកឥសី ធានស៊ីច្បាស់ណាស់, សេចក្តីអង់អាចក្លាហានដែលគាត់ធ្លាប់មានមកយូរហើយលោយបាត់ច្រើនណាស់ក្នុងខណៈនេះ ។

ឥសីធានស៊ីញញឹមស្ងួត ៖

– សាធុ ! សាធុ ! សូមឲ្យជួបសេចក្តីសង្ឃឹមដូចសំដីលោកប្អូនចុះ ។ សូមអញ្ជើញ !

អាស្រមសាំងឈីងមានសុទ្ធតែឥសីតែគេមិនមានក្រិត្យវិន័យតឹងតែងណាស់ណាទេ ។ ឥសីធានស៊ីពោលហើយលើកកែវស្រាក្រេបម្តង ១ ។ ស៊ីផធានឥតខានដឹងឬយល់ថាផ្កាកស្តាន់មានប្រយោជន៍អ្វីខ្លះទេ ។ នាយទឹកដល់គុណអ្នកស្រីរុនយូកសម្រេចចិត្តឥតបើគិតថា ៖

– បាបន្តិចទៀតយើងដណ្តើមផ្កាកស្តាន់ពីឥសីទៅជូនលោកស្រីស៊ីវិញ ។

ខណៈនោះនាយឃើញស៊ីឈីងក្រោកឈរថ្លែងវាចា ៖

– សូមជូនពរលោកបងឲ្យប្រកបតែនឹងសេចក្តីសុខគ្រប់ប្រការក្នុងដំណើរផ្សងព្រេងនេះ ។ ចំណែកខ្ញុំមានរឿងមួយគឺកូនប្រុសខ្ញុំ ត្រូវគេចាប់យកទៅហើយ, ខ្ញុំត្រូវទៅជួយរំដោះបន្ទាន់, មិនអាចបង្អង់ទីនេះយូរទេ ។ សូមលាសិនហើយ ។

ឥសីទាំងអស់ភ្ញាក់ព្រើត ។ ធានស៊ីសួរ ៖

– បងព្យាប្អូនបញ្ជូនកូនប្រុស ទៅហាត់រៀនយុទ្ធសិល្បៈឯភ្នំទឹកកកណា ! តើជនណាថ្លើមធំម្ល៉េះហ៊ានចាប់កូនប្រុសប្អូនឥតញញើតម្តាយឪពុក ព្រមទាំងក្រុមភ្នំទឹកកកដូច្នេះ ?

ស៊ីឈីងដកដង្ហើមយ៉ាងវែង ៖

–រឿងនេះវែងឆ្ងាយណាស់លោកបងអើយ ! មកពីខ្ញុំមិនបានអប់រំបានជាកូនខិលខូចបែបនេះ, រកបន្ទោសអ្នកដទៃមិនបានទេ ។

ស៊ីឈីងជាអ្នកក្លាហានមានឧត្តមគតិខ្ពង់ខ្ពស់គិតឃើញវែងឆ្ងាយណាស់, ទោះបីយ៉ាងវាន់ជានបប្ចូល

ក្ដីគ្នាផុតបំផ្លាញកូមិហ៊ានសាំងស៊ូរខូចជាដេះក៏គាត់មិនខឹងដែរ ព្រោះគាត់យល់ជាក់ថាដើមហេតុបណ្ដាល មកពីកូនប្រុសគាត់នោះឯង ។

ឥសីឈុនសុីចូលចិត្តជួយឈឺឆ្អាលរឿងអ្នកដទៃណាស់ កុំថាឡើយដល់រឿងស៊ីឈឹងជាប្អូនរួមគ្រូ នោះហើយគាត់ពោលថ្កើងៗភ្លាម :

- ប្អូនប្រុស, ប្អូនស្រី, សត្រូវណា ហ៊ានចាប់នាំកូនប្រុសរបស់ប្អូនទៅ ហាក់ដូចជាប្រមាថមើលងាយអាស្រមសាំងឈឹងទាំងមូល, ហេតុនេះបងមិនញញើតទេ ទោះសត្រូវធុនណាក៏បងជួយជ្រោមជ្រែងដែរ ។

ឥសីឈប់មួយខណៈទើបបន្ត:

- ហ៊ឺ ! សត្រូវចាប់កូនទៅបាត់ហើយប្អូននៅឆ្លៀតពេលមកសួរទុក្ខធុរៈ ក្រុមយើងទៀត ! នេះ ឯកភាពពិតប្រាកដដែលប្អូនសំដែងឲ្យឃើញថាប្អូននៅជាប់ជំពាក់ចិត្តលើក្រុមបក្សជានិច្ចទាំងអស់ ។ ចុះពួកយើងនៅស្ងៀមបានដែរចំពោះរឿងនេះ ? យើងមិនមែនអ្នកក្លាហានទេឬ ?

ឥសីឈុនសុីនឹកថា : អ្នកដែលហ៊ានចាប់កូនប្រុសម្ចាស់គូមិហ៊ានសាំងស៊ូពិតជាអ្នកខ្លាំងពូកែហើយ បានជាមិនញញើតប្ដីប្រពន្ធស៊ីឈឹងនិងក្រុមភ្នំទឹកកកដែលមានសមាជិកជាច្រើនលើសលុប ។ គាត់ឥតស្មានទាល់តែសោះថាអ្នកចង់ចាប់កូនប្រុសស៊ីឈឹងជាសិស្សក្រុមភ្នំទឹកកកតែម្ដង ។ ចំណែកស៊ីឈឹងវិញគាត់មិនចង់ប្រាប់រឿងអាស្រូវនៅក្នុងគ្រួសារឲ្យអ្នកដទៃដឹងខ្ចរខ្ចាយ ហើយមិនចង់ឲ្យឥសីខាងអាស្រមសាំងឈឹងពិបាកចិត្តពិបាកកាយផ្ទួនលើគ្រោះអាសន្នផ្ទាល់របស់ក្រុមបក្ស ទើបគាត់តបតាមសម្រួល:

- ចំពោះទឹកចិត្តស្មោះត្រង់ជួយឈឺឆ្អាលយើងខ្ញុំបែបនេះ ប្ដីប្រពន្ធខ្ញុំរំភើបចិត្តណាស់, ប៉ុន្តែរឿងនេះមិនទាន់ច្បាស់លាស់ទេ, ចាំខ្ញុំស៊ើបការណ៍មុនសិន ។ បើយើងខ្ញុំយល់ថាកម្លាំងផ្ទាល់ស្ដួចស្ដើង ខ្ញុំនឹងត្រឡប់មកទីនេះវិញរកពឹងពាក់បងប្អូន ។

ឥសីឈុនសុីងក់ក្បាល :

- ត្រូវហើយ ។ តែបងយល់ថាមិនបាច់ប្អូនពិបាកទេ, សុំផ្ញើដំណឹងតាមអ្នកណាម្នាក់មក អាស្រមសាំងឈឹងចាត់គ្នាទៅជួយភ្លាម !

ប្ដីប្រពន្ធស៊ីឈឹងក្រោកឈរថ្លែងអំណរគុណម្ដងទៀត, តែក្នុងចិត្តគេខ្លាចផ្សាណាស់ នឹកថា :

- ទោះបីក្រុមកុំទឹកកកធ្វើទណ្ឌកម្មកូនតុងយ៉ាងណា ក៏ប្ដីប្រពន្ធយើងសុខចិត្តទ្រាំទ្រទទួលដែរ, យើងមិនមកសុំជំនួយពីអាស្រមសាំងឈីងជាដាច់ខាត !

បន្ទាប់មកស៊ីឈីងនិងភរិយាលាឥសីចាកចេញទៅ ។ ឥសីបានស៊ី, ឈុងស៊ី និងឥសីឯទៀតជូនដំណើរប្ដីប្រពន្ធស៊ីឈីងដែរ ។ ស៊ីផានសម្ងំចាំមួយសន្ទុះឲ្យគេចេញផុតអស់ ទើបលោកផ្លោះចុះដីចេញទៅក្រៅហក់ឡើងលើដំបូលផ្ទះរត់ចេញពីបរិវេណអាស្រមសាំងឈីង ។ ជណ្ដឹងសួរថា:

- លោកប្រុសនិងលោកស្រីស៊ីថា សត្រូវចាប់កូនប្រុសគាត់, តើសត្រូវនោះជានរណា ? ផាកស្លាន់ជាល្បែងឥតប្រយោជន៍ ជណ្ដើមបានប្ដូរមិនបានហើយទៅ ។ លោកស្រីមានគុណលើយើងច្រើន យើងត្រូវជួយរកកូនប្រុសគាត់ឲ្យឃើញទើបគាត់សប្បាយចិត្ត ។ ចាំសួរគាត់មើលកូនគាត់អាយុប៉ុន្មាន រូបរាងយ៉ាងម៉េច ហើយអ្នកណាចាប់យកទៅ ?

មាណពលោតឡើងលើដើមឈើសម្ងំទៅអាស្រម ឃើញចង្កៀងគោមមួយផ្លូវភ្លឺផ្លុង ៗ គឺអស់លោកឥសីជូនដំណើរស៊ីឈីងដល់មាត់ទ្វាររបងហើយ ។ នាយនឹកថា :

- សេះលោកម្ចាស់ភូមិពីរនាក់នេះរត់លឿនណាស់. យើងត្រូវទៅមុនទើបទាន់ ។

គិតដូច្នេះហើយនាយលោតចុះពីដើមឈើរត់កួងសំដៅជាយភ្នំភូមិ ។ មិនទាន់ផុតព្រៃផង, នាយឮសម្រែងគំហក :

- អ្នកណាហ្នឹង ? ឈប់ឲ្យស្ងៀម !

ត្បិតកាលនៅតូចលើក្បាលឥសី នាយចំសម្ងំស្ងៀមឥតហានងក់ងើយឬងេងខ្ចប់ផ្ដើលគេ ។ ដល់កម្រើកខ្លួនលើដើមឈើឥសីគាត់ច្រើនព្ភាមតែគេមិនទាន់មាត់ ព្រោះប្ដីប្រពន្ធស៊ីឈីងជាភ្ញៀវមិនទាន់ចេញផុត ។ គ្រាន់តែភ្ញៀវឡើងសេះភ្លាមស៊ីបញ្ញាគុំគាត់ខ្មាណពជាប់គ្រញង់ ! ក្នុងបរិយាកាសស្ងាត់ងងឹតស្លូតឲ្យនោះ ស៊ីផានឃើញស្រពោលដាវភ្លឺផ្លេកចាក់ស្រោចមកលើនាយដុំចិស ។ ភ្លាមនោះឥសីពីររូបមកដល់មុខនាយស្រេច ។ ក្រោមរស្មីព្រះចន្ទស៊ីផានឃើញមុខឥសី តាវស៊ីស្រពិចស្រពិល នាយអររីកសួរ :

- លោកជាឥសីតាវស៊ីឬ ?

ឥសីស្រឡាំងកាំងឆ្ងល់ថាហេតុម៉េច... ស្គាល់គាត់

-ពិតមែន ។ លោកជាអ្នកណាដែរ ?

មាណពលូកដៃស្តាំទៅមុខ :

-សុំប្រគល់ផ្កាកស្លាន់ទាំងពីរមកឲ្យខ្ញុំ !

ឥសីចាស់ស៊ីទឹងក្រោធជាមួយដំហានគំហក :

-ឯងយកការនេះទៅ !

ព្រមទាំងយាវដាវចាក់ទៅនាយឈិប ! កាប្រមសាំងឈីងមានវិន័យតឹងរឹងតែងត្រង់មិនចាញ់ស្តាល់ សត្រូវច្បាស់លាស់គេមិនដែលវាយលុកត្រង់កន្លែងសំខាន់ភ្លាមទេ ពោះអ្នកនោះទទឹងទទែងយ៉ាងណា ក៏ដោយ ។ ស៊ីផានរង្គៀងខ្លួនគេចភ្លែតលូកដៃស្តាំចាប់ស្មាឥសីភ្លាម ។ ចាស់ស៊ីឃើញ មាណពមានកាយវិការរហ័សរហួនក៏បង្វិលដាវចាក់ស្មានាយប្អូន ។ ស៊ីផានឱនក្បាលត្បូល ក្រោមផ្លែដាវ ហើយលើកដៃស្តាំបំរើនកម្លាំងទះវៃ ខ្នាចស៊ីកាត់ដាច់ក ចាស់ស៊ីទុកខ្លួនធ្លាបធ្លាលប្រមុះផ្លូវ ក្បាលវិលមុខដួលផ្កាប់ក្រោយភ្លាមមួយរំពេច ។

ស៊ីផានបើកភ្នែកក្រឡេងក្រឡូងកាំង ឥសីមួយរូបទៀតយាវដាវបាក់ពីក្រោយវិញ ! មាណព ដឹងថាបាតដៃខ្លួនកំណាចណាស់, ប៉ះសាច់នរណាមិនបានទេព្រោះហើយនាយមិនហ៊ានតដៃក៏ហក់រឹង ទៅមុខ ។ ពុស្សូរភ្លាក ! គឺចុងដាវឥសីធ្លាក់ដាច់ខ្ទង់ការនាយ៉ាងដោយទាំងស្បែកសើចផង ។ ឥសីរូបនេះទន់ខ្សោយជាងឥសីចាស់ស៊ីទេ តែឃើញបងប្អូនស្លាប់យ៉ាងបវៀកគាត់ក៏ចង់ជួយជីវិតបងប្អូន ត្រូវចើបយាវដាវចាក់មក ។ ស៊ីផានគេចផុតគ្រៀតពេលលូកខ្ទុះដាវឥសីចាស់ស៊ីសិរីផងគុនតាំបិត ខាងក្រុមព្រះកាចិត្យផងកាត់ដាវឥសី ។ នៅក្រោមកម្លាំងណាគុជស្តុកស្តម្ភរបស់មាណពឥសីរូបនេះ ស្ពឹកដៃច្រាំមិនបានរបូតដាវហ៊ុំងផុតក្បាល ។

សិស្សខាងកាប្រមសាំងឈីងមិនមែនចេះតែគុនដាវមួយមុខទេ ។ កាលបើរបូតការុង ហើយគេបញ្ចេញស្នៀតចាប់ខ្ទាំជើពិសេសមកទៀតភ្លាម ។ ឥសីស្ទុះចូលទៅគ្រវីដៃទាំងគូចាប់ ខ្លួនងិងពោះស៊ីផានភ្លាម ។ មាណពឃើញឥសីចូលកៀកពេកនាយភ័យស្រែកភ្ញាក់សម្លេង ·

-កុំចូលមក !

ហើយនាយច្រឡំចាប់ដៃឥសីទាញចេញទៅវិញ ។ ជាតិពិសក្នុងបាតដៃនាយបញ្ចេញឥទ្ធិ ពលសាហាវភ្លាមបណ្តាលឲ្យឥសីដួលប្រូសតាមបណ្តោយដៃនាយហើយញ្ញៀជើងញ្ញៀដៃក្រញាង . . .

ស៊ីផានទ្រាំដើរស្រែកដោយសោកស្ដាយ :

– ហ៊ឺះ ! ខ្ញុំឥតមានចេតនាចង់សម្លាប់លោកទេ !

ពេលនេះព្រះសម្ដេចហួចខ្សួចខ្លាចពីចម្ងាយតិចៗទិសមកកាន់តែជិតហើយ ។ មាណពលូកដៃកាន់កាំផ្លាកស្ដាន់ក្នុងផងការពារស៊ីផាន់ហោចៅភ្លាមទើបរត់តាមផ្លូវ ដែលប្ដីប្រពន្ធស៊ីឈីនចេញដំណើរអម្បាញ់មិញ ។ នាយរត់ទៅៗ ... បានប្រហែលដប់យោជន៍ហើយ នៅតែមិនឮស្នូរជើងសេះទៀតក៏ដណ្ដឹងសួរ:

– សេះនេះដាយលឿនម៉្លេះហ្ន៎ ! មើលទៅយើងដេញមិនទាន់ទេ ។ ឬមួយលោកប្រុសលោកស្រីស៊ីឥតទៅតាមផ្លូវហ្នឹងទៅ ?

នាយរត់ទៅមុខមួយសន្ទុះធំទៀតទើបឮសម្លេងសេះកញ្ជ្រោល ។ គឺសេះសមិកសេះខ្មៅរបស់ប្ដីប្រពន្ធស៊ីឈីនចងជាប់នឹងដើមឈើក្បែរផ្លូវ ។ ស៊ីផានត្រេកអរណាស់ លូកផ្កាកស្ដាន់ចេញមកប្រុងស្រែកហៅអ្នកស្រីវុនយូស្រាប់តែឮស៊ីឈីនស្រែកមុន :

– អូនយូ៎ះ ការការនេះលួចតាមយើងកិតណាស់ពិតជាគ្មានបំណងល្អទេ, កំចាត់វាចោលសិនឬ?

មាណពភ្ញាក់ព្រើតនឹកថា :

– លោកប្រុសលោកស្រីមិនចូលចិត្តឲ្យយើងរត់តាមផ្លូវនេះទេតើ !

នាយឮសម្លេងអ្នកទាំងពីរច្បាស់ណាស់ តែរកមើលស្រមោលមិនឃើញត្រង់ណាសោះ ក៏កើតគំនិតបារម្ភខ្លាចវុនយូរាយលុកមក បន្ទំនាយឲ្យរាយសងវិញ លោតែនាយមិនប្រយ័ត្នអ្នកស្រីស្ទាប់អសារបង់ដោយសារបាតដៃនាយទៅវិវរហើយ ។ នាយខ្លាចជ្រុលដៃក៏ក្រាបពួនក្នុងគុម្ពស្មៅភ្លាម នឹកថាបើអ្នកស្រីចូលមកជិត នាយបោះផ្កាកស្ដាន់ឲ្យភ្លាមហើយរត់វិលជាការស្រេច ។

ភ្លាមនោះឮខ្យល់វូ ! ស្រមោលមួយស្ទុះផ្ទាតពីក្រោយគល់ឈើកាន់ដាវបង្អុកគុម្ពស្មៅ ស្រែកសន្ធាប់ :

– នែ ! ឯងតាមដានយើងមានការអី ? ចេញភ្លាមមក !

គឺជាសម្លេងអ្នកស្រីវុនយូ ។ ស៊ីផានប្រុងឆ្លើយស្រាប់តែឮការរុតសម្លាត់ជ្រែកខ្យល់វឹប ៗ ទម្រង់អ្នកស្រី ។ អ្នកស្រីលើកដាវគាសទម្លាក់ចោលអស់ ។ ពេលនោះទើបឃើញបុរសម្នា[illegible]ក់ការទៀតលោតចេញពីគុម្ពស្មៅយករកាំបិតកាច់សំដៅអ្នកស្រី ។ មាណ[illegible]ក់ព្រើតប្រហោងទះផ្ទុងដោយ

ឥតស្មានថាមានមនុស្សពួនក្នុងគុម្ពស្មៅដូចនាយដែរ ។ បុរសនេះមានកាយវិការរហ័សគ្រាន់បើ ត្រីកាំបិតដក់ខ្យល់វែបៗ... អ្នកស្រីគ្រាន់តែកាត់គេចប៉ុណ្ណោះ ។

ស៊ីឈីងដើរពីក្រោយដើមឈើចេញមក ក្រពាត់ដៃឈរមើលមួយស្របក់ក៏សួរ :

-នែ, ប្អូនប្រុសជាសិស្សរបស់លូស៊ីប៉ានៅភ្នំថៃសានមែនទេ ?

បុរសពាក់អាវខៀវគំហកតបវិញ :

-បើមែនវាយ៉ាងម៉េច ?

មាត់ឆ្លើយតែដៃគ្រវីគ្រវាត់កាំបិតឥតបន្អង់ ។ ស៊ីឈីងសើចញឹមៗ :

-យើងមិនធ្លាប់ចាត់ទុកនឹងលូស៊ីប៉ាមែន, តែក៏គ្មានគំនុំគុំគួននឹងគាត់ដែរ ។ ឯងតាមដានយើងប្រាំពីរប្រាំបីយោជន៍មកហើយ,តើឯងមានបំណងយ៉ាងណា ?

បុរសឆ្លើយព្រងើយ:

-យើងគ្មានពេលប្រាប់ឯង ...

ពេលនោះអ្នកស្រីសំដែងស្នៀតដាវយ៉ាងសាមញ្ញ បំភ័យបុរសពាក់អាវខៀវឲ្យរលះរលាំងទំការពារខ្លួនតាំងគ្រវែរកពេលឆ្លើយតទៅទៀតមិនបាន ។ ស៊ីឈីងសើចទៀត:

- ស្នៀតគុនកាំបិតរបស់លូស៊ីប៉ាភ្ញាក់ពូកែជាងគុនដាវរបស់ពួកយើងទៅទៀត ។ បើឯងហាត់រៀនមិនបានមួយចំណិតផង គ្រវែតាមយើងធ្វើអី ? ទម្លាក់កាំបិតសិនទៅ !

ស៊ីឈីងពោលដល់នេះ, អ្នកស្រីជាភរិយាបានបាក់មួយដាវត្រូវកដៃបុរសអាវខៀវល្មម ។ គាត់បង្វិលខ្លួនទៅក្រោយខ្នងបំបែរជើងដាវចុចជីពចរជាប់ ទើបឈប់ ។ ពុស្សូតឹងកាំបិតធ្លាក់ដល់ដីបុរសអាវខៀវកំរើកលែងរួច ។ ស៊ីឈីងសួរទាំងញញឹម :

- នែមិត្ត , ឯងឈ្មោះអី ?

បុរសនេះក្លាហានគ្រាន់បើ ទើបគំហកវិញ :

- បើចង់សម្លាប់ក៏សម្លាប់ម ក៏មិនបាច់សួរច្រើនទេ !

- ទេ, បើមិនព្រមប្រាប់ហើចុះ ។ មើលឥឡូវឯងចូលរួមនឹងក្រុមបក្សណាហើយ ? លោកគ្រូឯងមិនទាន់ដឹងទេឬ ?

(នៅមានត)

ដីកាលំនុកតាមលេខ ៣៤១ ចុះថ្ងៃទី ៣ ៦ - ៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់

Khmer Story Lovers